ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៤

លេខៈ......២១២.........អយក.មចទ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ជំរាបមក

## លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង

**កម្មវត្ថុ** : ការប្រើប្រាស់សាច់ប្រាក់សំរាប់រៀបចំប្រលងឆមាសទី ១

**យោង** : គោលការណ៍ណែនាំលេខ ១៩៣១ អយក.មចទ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ឆ្នាំ ២០០៣ សំរាប់ការអប់រំនៅមធ្យមសិក្សា ។

- ផែនការសកម្មភាព និងការបែងចែកថវិកា កម្មវិធីសកម្មភាពជាអាទិភាពឆ្នាំ ២០០៣ របស់អង្គភាពគ្រប់គ្រងថវិកានាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

ដោយនៅវង្វង់ខែកុម្ភៈ ឆ្នាំ ២០០៤នេះ គ្រប់គ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅ ត្រូវរៀបចំប្រលងឆមាសទី១ ឆ្នាំសិក្សា ២០០៣-២០០៤ ក្រសួងអប់រំ យុវជន និងកីឡាសូមណែនាំអនុវត្តដូចតទៅ ÷

១. សាច់ប្រាក់ដែលត្រូវយកមករៀបចំវិញ្ញាសាប្រលងឆមាស ពីថ្នាក់ទី ៧ ដល់ទី ១១ គឺត្រូវយកសាច់ប្រាក់ PAP ៣ ឆ្នាំ ២០០៣។ ចំពោះ គ្រប់គ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅត្រូវគ្រោងសាច់ប្រាក់ដែលត្រូវប្រើសំរាប់ប្រលងឆមាសទី១ នេះដោយគិតយ៉ាងច្រើនត្រឹម ១៣០០៛ សំរាប់សិស្សម្នាក់ រឺ ១៣% នៃសាច់ប្រាក់សរុបដែលនឹងត្រូវទទួលបានសំរាប់ PAP ៣ ឆ្នាំ ២០០៣។

២. សំរាប់ PAP ៣ ឆ្នាំ ២០០៣ ត្រូវគ្រោងចំនាយតាមគោលការណ៍ថ្មីជាក់ស្តែង គឺ ៣២% យ៉ាងតិច សំរាប់សំភារៈមូលដ្ឋាន ២៦% យ៉ាងច្រើនសំរាប់កែលំអបរិស្ថាន ២២% យ៉ាងច្រើនសំរាប់សកម្មភាពកីឡា សិល្បៈ រោងជាង កសិកម្ម គេហវិទ្យា ១៣% យ៉ាងច្រើនសំរាប់រៀបចំវិញ្ញាសាប្រលងឆមាសទី១ ឆ្នាំសិក្សា ២០០៣-២០០៤ និង ៧% យ៉ាងច្រើនសំរាប់ចំណាយផ្សេងៗឥតគ្រោងទុក។

សូមលោក លោកស្រី ប្រធានមន្ទីរផ្សព្វផ្សាយគោលការណ៍អនុវត្តជាក់ស្តែងសំរាប់ PAP ៣ ឆ្នាំ ២០០៣ នេះ អោយបានជ្រួតជ្រាបដល់គ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅក្រោមឱវាទ ដើម្បីគ្រោងសាច់ប្រាក់សំរាប់តំរូវការប្រលងឆមាសទី១ បានគ្រប់គ្រាន់ និងទាន់ពេលវេលា។

ក្រសួងសង្ឃឹមលើស្មារតីយកចិត្តទុកដាក់របស់លោក លោកស្រី ប្រធានមន្ទីរក្នុងការធ្វើអោយដំនើរការប្រលងឆមាសទី១ ឆ្នាំសិក្សា ២០០៣-២០០៤ នៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅប្រព្រឹត្តទៅដោយភាពរលូន និងមានប្រសិទ្ធភាពខ្ពស់។

ឋ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

ចំលងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- អង្គភាពពាក់ព័ន្ធក្រោមឳវាទក្រសួងអ.យ.ក
  "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ នា.មចទ